00946154

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 08 / 2013
ម៉ោង (Time/Heure): 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E284/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អនុស្សរណៈ:- អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៣

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហកម្មខ្ញុំក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ (E284/5)

១. សហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបញ្ជាក់ ថាតើគោលនយោបាយណាមួយ ក្នុងចំណោមគោលនយោបាយទាំងប្រាំដែលបង្កើតជាផ្នែកនៃសហកម្មខ្ញុំក្រិដ្ឋកម្មរួមតាមការចោទប្រកាន់ នឹងក្លាយជាប្រធានបទនៃការសម្រេចទាក់ទងអង្គហេតុជាក់ស្តែង ឬជាសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១។ សហព្រះរាជអាជ្ញាបានទទួចដល់អង្គជំនុំជម្រះឱ្យធ្វើការពិចារណាសម្រេចទៅលើការបង្កើត និងដំណើរការរបស់សហករណ៍ និងការដ្ឋាន ប៉ុន្តែមិនត្រូវពិចារណាសម្រេចទៅលើគោលនយោបាយកំណត់មុខសញ្ញាក្រុមជាក់លាក់ ព្រមទាំងការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍នោះទេ (ឯកសារ E284/5)។ មិនមានភាគីណាមួយបានដាក់ចម្លើយតបនោះទេ។

២. អង្គជំនុំជម្រះសូមរំឭកថា នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើកទីពីររបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានបំភ្លឺថា ការដាក់បញ្ចូលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ព្រមទាំងការកាប់សម្លាប់ដែលបានប្រព្រឹត្តិនៅទួលពោធិ៍ជ្រៃ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ "ផ្តល់លទ្ធភាព

ឲ្យមានការពិនិត្យបានលើប្រធានបទចំនួនពីរ ក្នុងចំណោមប្រធានបទចំនួនប្រាំ នៃដីកាដំណោះស្រាយ សំណុំរឿង ០០២ ដែលរួមមានការជម្លៀសដោយបង្ខំ និងការកាប់សម្លាប់ខ្មាំងនៃរបបនោះ" (ឯកសារ E284 កថាខណ្ឌ ១១៨)។ លើសពីនេះទៀត អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានានៅពេលចាប់ផ្តើមសំណុំរឿងនេះថា ការបង្ហាញក្នុងលក្ខណៈទូទៅអំពីគោលនយោបាយទាំងប្រាំគឺអាចអនុញ្ញាតបាន ដើម្បីផ្តល់លទ្ធភាពឲ្យមានការពិចារណាទៅលើវិធីសាស្ត្រនៃការបង្កើតគោលនយោបាយ (ឯកសារ E141 ទំព័រ ២)។ អង្គជំនុំជម្រះពិចារណាថា ក្នុងពេលនេះមិនចាំបាច់ត្រូវការការបញ្ជាក់បន្ថែមទៀតពាក់ព័ន្ធការប្រព្រឹត្តចំពោះគោលនយោបាយសហករណ៍និងការដ្ឋានកម្មករនោះទេ។

៣. អនុស្សរណៈនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះសំណើ E284/5។